## តើខ្ញុំអាចទាក់ទងអ្នកណាប្រសិនបើខ្ញុំមានកង្វល់អំពីករណីសំណុំរឿងរបស់ខ្ញុំដែលមិនអាចដោះស្រាយជាមួយបុគ្គលិកសង្គមកិច្ច FVS របស់ខ្ញុំ?

ប្រសិនបើអ្នកមានពាក្យបណ្ដឹង ឬមានកង្វល់អំពីថាតើករណីសំណុំរឿងរបស់អ្នកនឹងដោះស្រាយយ៉ាងដូចម្ដេច សូមទូរសព្ទទៅអ្នកគ្រប់គ្រងរបស់បុគ្គលិកសង្គមកិច្ច FVS របស់អ្នក។ ប្រសិនបើកង្វល់របស់អ្នកនៅតែមិនអាចដោះស្រាយបាន អ្នកអាចទូរសព្ទទៅអ្នកគ្រប់គ្រងតំបន់។

អ្នកក៏អាចទូរសព្ទទៅការិយាល័យទំនាក់ទំនងសមាជិកមណ្ឌលបោះឆ្នោតតាមលេខ 800-723-4831 ឬលេខ 360-902-8060 ដើម្បីសុំ ជំនួយពេលណាក៏បាន។

ការិយាល័យស៊ើបអង្កេតបណ្ដឹងគ្រួសារ និងកុមារនៃរដ្ឋ Washington ទទួលបានកង្វល់ និងពាក្យបណ្ដឹង និងបញ្ហាទាក់ទងនឹងសកម្មភាពរបស់ Department of Children, Youth, and Families (ក្រសួងកុមារ យុវជន និងគ្រួសារ) ហើយពួកគេមានសិទ្ធិអំណាចក្នុងការស៊ើបអង្កេតកង្វល់ផ្សេងៗ។ អាចទាក់ទងពួកគេបានតាមលេខ 800-571-7321។

### ចំពោះព័ត៌មានបន្ថែម សូមចូលទៅកាន់វេបសាយ៖

**https://dcyf.wa.gov/services/child-welfare-system/cps**



### ព័ត៌មានរបស់បុគ្គលិកសង្គមកិច្ច៖

ឈ្មោះ៖ ______________________________

ទូរសព្ទ៖ ______________________________

អ៊ីមែល៖ ______________________________

### ព័ត៌មានរបស់អ្នកគ្រប់គ្រងបុគ្គលិកសង្គមកិច្ច៖

ឈ្មោះ៖ ______________________________

ទូរសព្ទ៖ ______________________________

អ៊ីមែល៖ ______________________________

### ស្វែងរកការិយាល័យ DCYF ក្នុងមូលដ្ឋានរបស់អ្នក៖

**ស្កេនកូដ QR ឬចូលទៅកាន់វេបសាយ៖**
**https://apps-ca-ext.dcyf.wa.gov/CAOfficesPub/offices/general/OfficePick.asp**

*ប្រសិនបើអ្នកចង់បានច្បាប់ចម្លងនៃឯកសារបោះពុម្ពនេះដោយឥតគិតថ្លៃជាទម្រង់ ឬភាសាផ្សេងទៀត សូមទាក់ទងផ្នែកទំនាក់ទំនងមណ្ឌល DCYF តាមរយៈលេខ 1-800-723-4831 ឬអ៊ីមែល* ***communications@dcyf.wa.gov*** *។*

DCYF PUBLICATION CWP_0035 | DSHS 22-1751 CA (03-2025) Cambodian

# Family Voluntary Services (សេវាកម្មស្ម័គ្រចិត្តគ្រួសារ)

*ការពង្រឹងគ្រួសារតាមរយៈការភ្ជាប់ទៅកាន់សេវាកម្ម និងធនធានគាំទ្រ*



Washington State Department of
**CHILDREN, YOUTH & FAMILIES**

## តើ Family Voluntary Services (សេវាកម្មស្ម័គ្រចិត្តគ្រួសារ, FVS) ជាអ្វី?

FVS គឺជាកម្មវិធីដែលអនុញ្ញាតឱ្យឪពុកម្តាយ/អាណាព្យាបាលស្របច្បាប់ជ្រើសរើសចូលរួមក្នុងសេវាកម្ម ដើម្បីបំពេញតម្រូវការសុវត្ថិភាព សុខភាព និងសុខុមាលភាពរបស់កូនពួកគេ។

គោលដៅនៃ FVS គឺដើម្បីជួយគ្រួសារឱ្យចូលរួមក្នុងសេវាកម្មដែលបំពេញតម្រូវការរបស់គ្រួសារខណៈពេលដែលពង្រឹង និងរក្សាគ្រួសារឱ្យនៅជាមួយគ្នា។

បុគ្គលិកសង្គមកិច្ចធ្វើការជាមួយគ្រួសារដើម្បីបញ្ចប់ការវាយតម្លៃអំពីចំណុចខ្លាំង តម្រូវការ និងសុវត្ថិភាពកុមារ។ គ្រួសារអាចជ្រើសរើសឈប់ធ្វើការជាមួយ Department of Children, Youth, and Families (ក្រសួងកុមារ យុវជន និងគ្រួសារ, DCYF) នៅពេលណាក៏បាន។ ប្រសិនបើគ្រួសារជ្រើសរើសបញ្ឈប់សេវាកម្ម FVS នោះ បុគ្គលិកសង្គមត្រូវបានតម្រូវឲ្យវាយតម្លៃកម្រិតសុវត្ថិភាព និងហានិភ័យមុនពេលបិទសំណុំរឿងនេះ។ ប្រសិនបើមានតម្រូវការដែលមិនទាន់ឆ្លើយតបទាក់ទងនឹងសុវត្ថិភាពកុមារ DCYF អាចស្នើសុំអន្តរាគមន៍ពីតុលាការដោយដាក់ញត្តិកូននៅក្នុងបន្ទុក។

## តើ FVS ដំណើរការយ៉ាងដូចម្តេច?

FVS អាចត្រូវបានផ្តល់ជូនបន្ទាប់ពីករណីសំណុំរឿង CPS នៅពេលដែលសេវាកម្ម និងធនធានអាចគាំទ្រគ្រួសារដើម្បីធានានូវសុវត្ថិភាពកុមារ និងស្ថិរភាពគ្រួសារ។

គ្រួសារក៏អាចស្នើសុំសេវាកម្ម FVS ក្នុងគ្រាមានតម្រូវការបានផងដែរដោយទូរសព្ទទៅ DCYF។





## ក្តីរំពឹង

### អ្វីដែលត្រូវរំពឹងពីបុគ្គលិកសង្គមកិច្ច FVS របស់អ្នក

- ពួកគេនឹងប្រព្រឹត្តចំពោះអ្នក និងក្រុមគ្រួសាររបស់អ្នកដោយការគោរព។
- ដើម្បីធ្វើការជាមួយអ្នក និងធ្វើផែនការដើម្បីរក្សាសុវត្ថិភាពកូនរបស់អ្នក និងធ្វើឱ្យប្រាកដថាកូនរបស់អ្នកបានបំពេញតាមតម្រូវការមូលដ្ឋានរបស់ពួកគេ។
- ពួកគេនឹងផ្តល់សេវាកម្មជាក់លាក់សម្រាប់អ្នក និងគ្រួសាររបស់អ្នកដូចជាការអប់រំអំពីការធ្វើតួនាទីឪពុកម្តាយ ការផ្តល់ប្រឹក្សា ឬការព្យាបាល។ សូមចូលទៅកាន់វេបសាយ DCYF សម្រាប់បញ្ជីសេវាកម្ម និងធនធានដ៏ទូលំទូលាយបន្ថែមទៀត។
- ពួកគេនឹងជួបជាមួយគ្រួសាររបស់អ្នក និងជាលក្ខណៈឯកជនជាមួយកុមារនៅក្នុងផ្ទះរបស់អ្នកយ៉ាងហោចណាស់មួយទៅពីរដងក្នុងមួយខែ។
- ពួកគេនឹងទាក់ទងអ្នកផ្តល់សេវា ដៃគូសហគមន៍ គ្រួសារ និងមិត្តភក្តិ (ដោយមានការអនុញ្ញាតពីអ្នក) ដើម្បីទទួលបានទស្សនៈខាងក្រៅអំពីអ្នក និងវឌ្ឍនភាពនៃគ្រួសាររបស់អ្នក។
- ពួកគេនឹងនិយាយជាមួយអ្នកអំពីសុវត្ថិភាពផ្ទាល់ខ្លួន និងសុវត្ថិភាពរបស់ទារក/កុមារចេះដើរតេះតះ។
- ប្រសិនបើកូនរបស់អ្នកត្រូវបានសង្ស័យថាត្រូវបានកេងប្រវ័ញ្ចរកស៊ីផ្លូវភេទ ពួកគេនឹងជួយអ្នកក្នុងការបំពេញការវាយតម្លៃ និងផ្តល់សេវាកម្ម។
- ពួកគេនឹងលើកទឹកចិត្តអ្នកឱ្យធ្វើការជាមួយមិត្តភក្តិមានស្ថានភាពប្រហាក់ប្រហែល ឬចូលរួមក្រុមគាំទ្រនៅពេលណាដែលមាន។

### អ្វីដែលបុគ្គលិកសង្គមកិច្ច FVS របស់អ្នករំពឹងពីអ្នក

- ដើម្បីចូលរួមក្នុងដំណើរការវាយតម្លៃ និងជួយបង្កើតផែនការពង្រឹងសុខុមាលភាពគ្រួសារ និងស្ថិរភាពរយៈពេលវែងរបស់គ្រួសារអ្នក។
- ដើម្បីអនុវត្តតាមផែនការសុវត្ថិភាព (ប្រសិនបើអ្នកមានផែនការ)។
- ដើម្បីចូលរួមក្នុងសេវាកម្មដើម្បីពង្រឹងសុខុមាលភាពគ្រួសារ និងស្ថិរភាពរយៈពេលវែងរបស់គ្រួសារអ្នក។
- ដើម្បីអនុញ្ញាតឱ្យបុគ្គលិកសង្គមកិច្ច FVS ជួបជាមួយកូនៗរបស់អ្នកជាលក្ខណៈឯកជន។
- ដើម្បីជួបជាមួយបុគ្គលិកសង្គមកិច្ច FVS ជាទៀងទាត់។
- ដើម្បីឱ្យបុគ្គលិកសង្គមកិច្ច FVS បានជ្រាបអំពីការផ្លាស់ប្តូរណាមួយនៅក្នុងស្ថានភាពរបស់អ្នក។
- ដើម្បីចុះហត្ថលេខាលើលិខិតអនុញ្ញាតឲ្យចេញផ្សាយព័ត៌មានសម្រាប់អ្នក និងកូនរបស់អ្នក។
- ដើម្បីចែករំលែកចំណុចខ្លាំង តម្រូវការ និងកាលៈទេសៈរបស់គ្រួសារអ្នក។